**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ.០.ស.ជ.ណ. ៩០៣៤

# សេចក្ដីណែនាំ
## ស្ដីពី
## បែបបទ និងនីតិវិធី នៃការផ្លាស់ប្ដូរសមាជិកក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

អនុលោមតាមច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង ព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/៥៧៣ ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៩ ដែលបានកំណត់ការទទួលស្គាល់ និងការផ្លាស់ប្ដូរសមាជិកក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រសួងមហាផ្ទៃសូមធ្វើការណែនាំអំពីបែបបទ និងនីតិវិធីនៃការផ្លាស់ប្ដូរសមាជិកក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដូចខាងក្រោម :

### ១- លក្ខខណ្ឌ និងការបំពេញបែបបទនៃការផ្លាស់ប្ដូរសមាជិកក្រុមប្រឹក្សា

អនុវត្តតាមបទប្បញ្ញត្តិមាត្រា២២ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាចត្រូវបានធ្វើការផ្លាស់ប្ដូរក្នុងករណីមួយចំនួន ដូចខាងក្រោម :

១- សាមីខ្លួនបាត់បង់លក្ខណសម្បត្តិ និង លក្ខខណ្ឌសម្រាប់ឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា

២- សាមីខ្លួនបានសុំលាឈប់ពីក្រុមប្រឹក្សាតាមការដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ

៣- សាមីខ្លួនទទួលមរណភាព

៤- សាមីខ្លួនមិនបានចូលរួមក្នុងកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាជាប់ៗគ្នា ចាប់ពីពីរ(០២)ដង ឡើងទៅ ដោយគ្មានច្បាប់អនុញ្ញាត

៥-សាមីខ្លួនត្រូវបានបណ្ដេញចេញពីសមាជិកក្រុមប្រឹក្សា អនុលោមតាមច្បាប់ នីតិវិធី ឬបទបញ្ជាផ្ទៃក្នុង ឬក្រមសីលធម៌របស់ក្រុមប្រឹក្សា

៦- សាមីខ្លួនត្រូវតុលាការផ្ដន្ទាទោសពីបទឧក្រិដ្ឋ ឬ បទមជ្ឈិមណាមួយ

៧- សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយណាមួយ ។/.

ផ្អែកតាមករណីនីមួយៗខាងលើ រាល់ការស្នើសុំផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សា ត្រូវបំពេញបែបបទ ដូចបាន
កំណត់ខាងក្រោម ៖

១- ករណីមានសមាជិកក្រុមប្រឹក្សាបាត់បង់លក្ខណសម្បត្តិ និងលក្ខខណ្ឌសម្រាប់ឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា សំណើសុំផ្លាស់ប្តូរសាមីខ្លួន ត្រូវភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់ ឬរបាយការណ៍ពីមូលហេតុនៃការបាត់បង់លក្ខណសម្បត្តិ និងលក្ខខណ្ឌសម្រាប់ឈរឈ្មោះជាបេក្ខជន ទៅតាមករណីជាក់ស្តែងនីមួយៗ តាមមាត្រា២១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង មាត្រា ១៧ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ។

២- ករណីសមាជិកក្រុមប្រឹក្សាមានបំណងសុំលាឈប់ពីសមាជិកក្រុមប្រឹក្សា សាមីខ្លួនត្រូវធ្វើពាក្យសុំជាលាយលក្ខណ៍អក្សរទៅប្រធានក្រុមប្រឹក្សាសាមី ទន្ទឹមនោះការលើកសំណើសុំផ្លាស់ប្តូរសាមីខ្លួន ត្រូវភ្ជាប់មកជាមួយនូវពាក្យស្នើសុំរបស់សមាជិកក្រុមប្រឹក្សានោះ ។

៣- បើមានសមាជិកក្រុមប្រឹក្សាទទួលមរណភាព សំណើសុំផ្លាស់ប្តូរសាមីខ្លួន ត្រូវភ្ជាប់មកជាមួយនូវសេចក្តីចម្លងសំបុត្រមរណភាព ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច ។

៤- ករណីសមាជិកក្រុមប្រឹក្សាណា ដែលមិនបានចូលរួមក្នុងកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាជាប់ៗគ្នាចាប់ពីពីរ( ០២)ដងឡើងទៅ ដោយគ្មានច្បាប់អនុញ្ញាត សំណើសុំផ្លាស់ប្តូរសាមីខ្លួន ត្រូវភ្ជាប់មកជាមួយនូវកំណត់ហេតុ និងបញ្ជីវត្តមាននៃកិច្ចប្រជុំក្រុមប្រឹក្សាទាំងពីរលើក ។

៥-ករណីមានសមាជិកក្រុមប្រឹក្សាណា ត្រូវបានបណ្តេញចេញពីសមាជិកក្រុមប្រឹក្សា អនុលោមតាមច្បាប់ នីតិវិធី ឬបទបញ្ជាផ្ទៃក្នុង ឬក្រមសីលធម៌របស់ក្រុមប្រឹក្សានោះ សំណើសុំផ្លាស់ប្តូរសាមីខ្លួន ត្រូវភ្ជាប់មកជាមួយនូវរបាយការណ៍ និងកំណត់ហេតុនៃការប្រជុំអនុម័តបណ្តេញសាមីខ្លួនចេញពីក្រុមប្រឹក្សា ។

៦- ប្រសិនបើមានសមាជិកក្រុមប្រឹក្សាត្រូវបានតុលាការផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬ បទមជ្ឈិមណាមួយ សំណើសុំផ្លាស់ប្តូរសាមីខ្លួនត្រូវភ្ជាប់មកជាមួយសាលក្រម ឬសាលដីកាស្ថាពររបស់ស្ថាប័នតុលាការ ។

៧- ក្នុងករណីមានសមាជិកក្រុមប្រឹក្សាត្រូវបានបញ្ឈប់ពីសមាជិក នៃគណបក្សនយោបាយរបស់ខ្លួន គណបក្សនយោបាយសាមីត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សាដោយភ្ជាប់មកជាមួយ នូវលិខិត ឬសេចក្តីសម្រេចរបស់គណបក្សនយោបាយនោះ ដែលកំណត់បញ្ឈប់សាមីខ្លួនពីសមាជិកភាពនៃគណបក្សនយោបាយរបស់ខ្លួន ស្របតាមលក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុងនៃគណបក្សនយោបាយសាមី ។

## ២.បែបបទ និងនីតិវិធីនៃការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាតាមប្រភេទនីមួយៗ

ក្នុងករណីដែលសមាជិកណាម្នាក់បាត់បង់សមាជិកភាពពីសមាជិកក្រុមប្រឹក្សា តាមលក្ខខណ្ឌដូចបានរៀបរាប់ខាងលើ ក្នុងអំឡុងពេលនៃអាណត្តិរបស់ក្រុមប្រឹក្សា ត្រូវជ្រើសរើសបេក្ខជនដែលមានឈ្មោះលំដាប់បន្ទាប់ក្នុងបញ្ជី

បេក្ខជនរបស់សមាជិកក្រុមប្រឹក្សាដែលបាត់បង់សមាជិកនោះមកជំនួស សម្រាប់រយៈពេល នៃអាណត្តិដែលនៅសល់ តាមគោលការណ៍ដូចមានចែងក្នុងមាត្រា២៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។ ក្រសួងមហាផ្ទៃនឹងសម្រេចប្រកាសពីការបាត់បង់សមាជិកភាព និងការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សា ដោយយោងទៅលើលក្ខខណ្ឌដូចបានរៀបរាប់ខាងលើ ។

**បែបបទ និងនីតិវិធីនៃការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាប្រភេទនីមួយៗ ត្រូវបានកំណត់ដូចខាងក្រោម ៖**

**ក -ការផ្លាស់ប្តូរក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត**

នៅពេលមានសមាជិកក្រុមប្រឹក្សារាជធានី ឬក្រុមប្រឹក្សាខេត្ត បាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវរៀបចំបែបបទ លើកសំណើសុំផ្លាស់ប្តូរជាបន្ទាន់ មករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីពិនិត្យ និង សម្រេច ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធតាមការកំណត់ខាងលើ ។

ប្រធានក្រុមប្រឹក្សាត្រូវរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួន អំពីការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សានោះ ក្នុងចន្លោះកិច្ចប្រជុំសាមញ្ញមួយទៅកិច្ចប្រជុំសាមញ្ញមួយ នៃក្រុមប្រឹក្សារបស់ខ្លួន ។

**ខ -ការផ្លាស់ប្តូរក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ**

ករណីមានសមាជិកក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ បាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌសាមី ត្រូវលើកសំណើសុំផ្លាស់ប្តូរជាបន្ទាន់ មកក្រសួងមហាផ្ទៃ ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធតាមការកំណត់ខាងលើ ។ ប្រធានក្រុមប្រឹក្សាត្រូវរាយការណ៍អំពីការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សា ក្នុងចន្លោះកិច្ចប្រជុំសាមញ្ញមួយ ទៅកិច្ចប្រជុំសាមញ្ញមួយ នៃក្រុមប្រឹក្សារបស់ខ្លួន ។

សំណើសុំផ្លាស់ប្តូរនេះត្រូវបញ្ជូនជាបន្ទាន់មកអភិបាលរាជធានី ឬអភិបាលខេត្ត ។ អភិបាលរាជធានី ឬអភិបាលខេត្ត ត្រូវធ្វើការត្រួតពិនិត្យឯកសារដែលស្នើសុំផ្លាស់ប្តូរនោះ ឱ្យប្រាកដ ច្បាស់លាស់ អំពីករណីដែលតម្រូវឱ្យមានការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សារូបនោះ និងធានាថា អ្នកដែលត្រូវប្តូរជំនួសមានលក្ខណៈត្រឹមត្រូវស្របតាមនីតិវិធីកំណត់ ។ ករណីពិនិត្យឃើញត្រឹមត្រូវហើយ អភិបាលរាជធានី ឬអភិបាលខេត្ត ត្រូវធ្វើដីកាអមបញ្ជូនឯកសារទាំងអស់ ដែលបានទទួលពីក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ មករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីពិនិត្យ និងសម្រេចឱ្យបានទាន់តាមពេលវេលាដែលកំណត់ក្នុងច្បាប់ ។

ករណីពិនិត្យឃើញមានការខ្វះខាតលក្ខខណ្ឌណាមួយ ដែលច្បាប់បានតម្រូវ អភិបាលរាជធានី ឬអភិបាលខេត្ត ត្រូវធ្វើលិខិតជាលាយលក្ខណ៍អក្សរជម្រាបទៅក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដែលពាក់ព័ន្ធអំពីការខ្វះខាតនោះ ជាបន្ទាន់ ហើយស្នើសុំឱ្យធ្វើការបំពេញចំណុចខ្វះខាតនោះ ស្របតាមច្បាប់តម្រូវ ក្នុងពេលវេលាជាក់លាក់

ដើម្បីធានាឱ្យការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាបានសមស្របទៅតាមរយៈពេលដែលកំណត់ក្នុងច្បាប់ ។ អភិបាលរាជធានី ឬអភិបាលខេត្តត្រូវធ្វើដីកាអម ដោយភ្ជាប់នូវសំណើរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឯកសារពាក់ព័ន្ធ រួមនិងលិខិតនានា ដែលពាក់ព័ន្ធនឹងការបំពេញចំណុចខ្វះខាត មករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ពិនិត្យ និង សម្រេច ។ អភិបាលរាជធានី ឬអភិបាលខេត្ត ត្រូវធ្វើសេចក្តីរាយការណ៍អំពីករណីនៃការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ រៀងរាល់កិច្ចប្រជុំសាមញ្ញ នៃក្រុមប្រឹក្សារបស់ខ្លួន ។

ទទួលបានសេចក្តីណែនាំនេះ ក្រុមប្រឹក្សា និងគណៈអភិបាលរាជធានី ខេត្ត ក្រុមប្រឹក្សា និងគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងអង្គភាពដែលពាក់ព័ន្ធ ត្រូវចាត់ចែងផ្សព្វផ្សាយ និងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ [illegible] ឆ្នាំ ២០០៩

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**<u>ចម្លងជូន</u> :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- គណបក្សនយោបាយពាក់ព័ន្ធ

  *( <u>ដើម្បីជូនជ្រាបជាព័ត៌មាន</u> )*
- សាលារាជធានី ខេត្ត

  *( <u>ដើម្បីអនុវត្ត និងចម្លងចែកសាលាក្រុង ស្រុក ខណ្ឌ</u> )*
- ឯកសារ កាលប្បវត្តិ